**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * * *

នៅព្រឹកថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៩ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអនុញ្ញាតឲ្យ **ឯកឧត្តម** Kreso Glavac ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋក្រូអាស៊ីប្រចាំកម្ពុជា មាននិវេសនដ្ឋាននៅទីក្រុង គូឡាឡាំពួ ចូលជួបសម្តែងការគួរសម និងជម្រាបលាក្នុងឱកាសដែលឯកឧត្តមបានបញ្ចប់បេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអរគុណចំពោះការខិតខំប្រឹងប្រែងរបស់ឯកឧត្តមឯកអគ្គរដ្ឋទូត ក្នុងការជំរុញទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំថែមទៀត។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីទំនាក់ទំនងការទូតដ៏យូរលង់រវាងកម្ពុជា និងក្រូអាស៊ី ដែលបានចាប់ផ្តើមឡើងតាំងពីឆ្នាំ ១៩៥៧ ក្នុងអតីតសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី និងត្រូវធ្វើឲ្យកាន់តែរីកចំរើនថែមទៀតដើម្បីជាគុណប្រយោជន៍ដល់ប្រជាជនទាំងពីរ ព្រមទាំងបានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងវិស័យទេសចរណ៍ កំពង់ផែ ការដោះមីន។ល។ នៅក្នុងទិសដៅនេះ កម្ពុជាកំពុងពិចារណាក្នុងការតែងតាំងឯកអគ្គរាជទូត ឲ្យទទួលបន្ទុកប្រទេសក្រូអាស៊ីផងដែរ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងអំពីដំណើរទស្សនកិច្ចផ្លូវការថ្មីៗនេះរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសឆែក ហុងគ្រី និងប៊ុលហ្គារី ដែលជាការបង្ហាញពីការខិតខំតភ្ជាប់ និងពង្រឹងទំនាក់ទំនងឡើងវិញជាមួយមិត្តចាស់ជាប្រពៃណីរបស់កម្ពុជា។ ជាមួយគ្នានេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីអាទិភាពជាចំបង ក្នុងការជំរុញទំនាក់ទំនងពាណិជ្ជកម្ម និងសេដ្ឋកិច្ច រវាងប្រទេសទាំងពីរ និងសារៈប្រយោជន៍នៃការរៀបចំយន្តការពិគ្រោះយោបល់នយោបាយរវាងក្រសួងការបរទេសទាំងពីរ សម្រាប់ការពិនិត្យមើលលើកិច្ចសហប្រតិបត្តិការនាពេលកន្លងមក និងការកំណត់ទិសដៅនៃកិច្ចសហប្រតិបត្តិការនាពេលអនាគត ព្រមទាំងការផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិនានា ដែលផ្តល់ជាផលប្រយោជន៍រួមរបស់ប្រទេសទាំងពីរ។

ជាការឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានផ្តល់ការអនុញ្ញាតចូលជួបសម្តែងការគួរសម និងជម្រាបលា ក៏ដូចជាបានផ្តល់នូវកិច្ចសហប្រតិបត្តិការដ៏ល្អក្នុងពេលបំពេញបេសកកម្មរយៈពេល ៤ ឆ្នាំកន្លងមកនេះ។ ឯកឧត្តមឯកអគ្គរដ្ឋទូត បានបញ្ជាក់ថាក្នុងរយៈពេលកន្លងមក ឯកឧត្តមបានជួបប្រជុំជាមួយក្រសួងពាក់ព័ន្ធ និងដៃគូវិនិយោគមួយចំនួនរបស់កម្ពុជាផងដែរ ហើយបានសង្កេតឃើញពីចំណុចសកម្មនៃក្រុមធុរកិច្ចកម្ពុជា។ ឯកឧត្តមឯកអគ្គរដ្ឋទូត ក៏យល់ស្របដូចការលើកឡើងរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី

ដែលថាប្រទេសទាំងពីរមានចំណុចរួមគ្នាជាច្រើនដូចជា សាវតាប្រវត្តិសាស្ត្រ និងទំនាក់ទំនងនយោបាយជាដើម និងឯកភាពលើសារៈសំខាន់នៃការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតកិច្ចពិគ្រោះយោបល់នយោបាយរវាងក្រសួងការបរទេសទាំងពីរ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានគូសបញ្ជាក់ថា ក្រូអាស៊ីនឹងក្លាយជាប្រធានប្តូរវេននៃសហភាពអឺរ៉ុបពីខែមករាដល់ខែកក្កដា ឆ្នាំ ២០២០ ខាងមុខ។ **ឯកឧត្តម**យល់ថាជាឱកាសសមស្របក្នុងការលើកកំពស់ទំនាក់ទំនងការទូតមួយកម្រិតថែមទៀតជាមួយកម្ពុជា ដោយសូមស្នើអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ទៅបំពេញទស្សនកិច្ចនៅក្រូអាស៊ី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានទទួលយកការអញ្ជើញដោយក្តីសោមនស្សរីករាយ ហើយនឹងស្វែងរកពេលវេលាសមស្របនៅពេលខាងមុខ ។

ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងកម្ពុជា និងសហភាពអឺរ៉ុប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីការបន្តកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការល្អជាមួយសហភាពអឺរ៉ុប ទោះបីកម្ពុជាមានបញ្ហាខ្លះៗជាមួយសហភាពអឺរ៉ុបក៏ដោយ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានគូសបញ្ជាក់យ៉ាងច្បាស់ថា ក្រូអាស៊ីជាមិត្តរបស់កម្ពុជា ក្រូអាស៊ីនឹងគាំទ្រកម្ពុជា ហើយព្រមទាំងខិតខំពន្យល់សមាជិកសហភាពអឺរ៉ុបផ្សេងទៀត ឲ្យយល់ពីកម្ពុជាកាន់តែប្រសើរផងដែរ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃអង្គារ ៩ រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៩